# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Aug-2012, 12:27
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ:/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើរបស់លោក ខៀវ សំផន សុំដាក់ឯកសារថ្មីមួយ បញ្ចូលក្នុងការពិភាក្សាដេញដោល

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Artur VERCKEN

លោក Jacques VERGÈS

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

| | |
|---|---|
| កញ្ញា Mathilde CHIFFERT | **មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| កញ្ញា អ៊ុំ ស្រីផាត | |
| កញ្ញា Soumeya MEDJEBEUR | **ក្រុមមេធាវីខាងការពារក្តីទាំងអស់** |

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ មេធាវីការពារក្តីរបស់លោក ខៀវ សំផន បានអានអត្ថបទកាសែតមួយចុះកាលបរិច្ឆេទនៅថ្ងៃដដែលនោះ ដែលលើកឡើងពីសម្តីរបស់សាក្សី រចឹម តុន ហៅ ភី ភួន (TCW-564) ក្រោយពីបានបញ្ចប់ការផ្តល់សក្ខីកម្មរបស់ខ្លួន នៅតុលាការ កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២ ។[1]

២. នៅថ្ងៃនេះ មេធាវីការពារក្តី សុំឲ្យដាក់ឯកសារនោះ បញ្ចូលទៅក្នុងកិច្ចពិភាក្សាដេញដោល ហើយសូមឲ្យទទួលយកឯកសារនោះថា ជាភ័ស្តុតាង ដោយអនុលោមទៅតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង។[2]

៣. គេមិនអាចប្រកែកបានទេថា មានអត្ថបទកាសែតនេះនៅមុនពេលបើកសវនាការ ហើយមេធាវីការពារក្តី នឹងមិនអាចរកអត្ថបទនោះមកបាន មុននឹងការចេញផ្សាយថ្មីៗនេះ ដោយការយកចិត្តទុកដាក់នោះឡើយ។

៤. ឯកសារថ្មីនេះ មានសារៈសំខាន់ណាស់ សម្រាប់ការស្វែងរកការពិត និងវាបំពេញតាមលក្ខណៈសម្បត្តិដែលមានចែងនៅក្នុងវាក្យខណ្ឌទី៣ នៃវិធាន៨៧ [3] ព្រោះថា នៅក្នុងអត្ថបទនោះ លោក រចឹម តុន ហៅ ភី ភួន បាននិយាយអំពីពាក្យសម្តីដែលគាត់បានលើកឡើងនៅក្នុងសវនាការ។ អត្ថបទនោះបានចង្អុលបង្ហាញជាពិសេសថា ៖

> *"Reached yesterday, Mr. Phuon confirmed that he would not stand by his evidence, insisting he had never said that Mr. Namhong was in charge of the*

---

[1] អត្ថបទកាសែត *Cambodia Daily* ក្រោមចំណងជើងថា *« KRT witness recants Hor Namhong claim »* សរសេរដោយ ឆន ចាន់ស៊ី និង Julia Wallace ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ ដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។

[2] "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំ ជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែល មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុ នៃការស្នើសុំនេះឲ្យបានច្បាស់លាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាម ខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។ ។"

[3] "(...) អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា ៖ក- មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា។ ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ ។ គ-មិនសមស្រប សំរាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង ។ ឃ-ច្បាប់មិនអនុញ្ញាត ឬ ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។"

*Boeung Trabek prison camp, where diplomats and intellectuals who returned to Democratic Kampuchea were held. "I did not say this answer. I did not even say the word prison at all. I was asked at the same questions again and again, for long hours. I was sick and I was confused with the questions," he said."*

*"Mr. Phuon, who is the former deputy government of Banteay Meanchey province's Malai district, a longtime Ieng Sary stronghold, added that he would not agree to return to the tribunal if asked to clarify his testimony – unless the government wanted him to go. "I won't go because I am not well. I have diarrhea and vomiting. I don't want to go, but if the government needs me, I would go."*

៥. ពាក្យពេចន៍ដែលបាននិយាយជាសាធារណៈ បន្ទាប់ពីធ្វើសក្ខីកម្ម ដោយបានស្បថរួច ចំពោះមុខអង្គជំនុំជម្រះបែបនេះ វាប៉ះពាល់ដោយផ្ទាល់ទៅនឹងការគួរឲ្យជឿជាក់បាននៃសក្ខីកម្មរបស់សាក្សីដាក់បន្ទុកនេះ។ អត្ថបទដែលជាកម្មវត្ថុនៃសំណើសុំឲ្យដាក់បញ្ចូលជាភស្តុតាងនេះ ពិតជាមានលក្ខណៈសមស្របបំផុត និងមានសារៈសំខាន់គ្រប់គ្រាន់ ដើម្បីយកទៅប្រើប្រាស់ នៅក្នុងការកាត់សេចក្តី និងដើម្បីជួយដល់អង្គជំនុំជម្រះ ក្នុងការវាយតម្លៃអំពីភាពឲ្យជឿជាក់បាន នៃសេចក្តីថ្លែងរបស់លោក រចឹម តុន ។

៦. **អាស្រ័យហេតុនេះ** ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន សូមស្នើសុំអង្គជំនុំជម្រះសាលាដំបូង មេត្តា**បញ្ចូល**ឯកសារថ្មីនេះ ទៅក្នុងកិច្ចពិភាក្សាដេញដោល **ទទួលយក** អត្ថបទនោះមកធ្វើជាភស្តុតាង និងដាក់ឈ្មោះឯកសារនោះ ជាមួយនិងលេខកូដ E3។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Artur VERCKEN<br>មេធាវី Jacques VERGÈS | ភ្នំពេញ<br>ប៉ារីស<br>ភ្នំពេញ<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |